**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

*****

**********

សំណុំរឿងរដ្ឋប្បវេណី

លេខ: ២២

ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០១

**សាលដីកា**

លេខ: ២១៥

ចុះថ្ងៃទី០៦ខែតុលាឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ស៊ិន ឌីម ជាចៅក្រមរបាយការណ៍

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក ឈឹម ស៊ីផល ជាចៅក្រម

៦- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៧- លោក យស់ សូខឿន ជាចៅក្រម

៨- លោក ប៉ែន សារឿន ជាចៅក្រម

៩- លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា **ហុក សុខឆុល**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ រវាង:

-ដើមចោទឈ្មោះ**ខួន ម៉េងឆាយ** (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរនាយកសាលាជីដុះ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

និងចុងចំលើយឈ្មោះ**ស៊ឹម ហ៊ុន** អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម "តំណាងដោយឈ្មោះ កែវ ណារី " ។

**ចម្ងល់ចោទសួរ:** ប្ដឹងទាមទារច្រកចេញចូល

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ៤៦១ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោក ងួន ម៉េឆាយ ប្ដឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១១-០១-១៩៩៧ លោក ងួន ម៉េងឆាយ ប្ដឹងពីអ្នកស្រី ស៊ឹម ហ៊ុន ថា : បានបិទច្រកចេញចូលខាងក្រោយសាលារៀនរបស់លោកដោយហេតុថា ច្រកចេញចូលនេះមានតាំងពីមុនឆ្នាំ ១៩៧៥មកម្លេះ ហើយឥឡូវគ្រួសារអ្នកស្រីយកធ្វើជារបស់អ្នកស្រី ។ ហេតុនេះ ទើបលោកប្ដឹងសុំអោយបើកច្រកចេញចូលឡើងវិញ ។

បានឃើញសាលក្រមរបៀបលេខ៧៧ "គ" ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

-អោយសុរិយោដីខេត្តកំពង់ចាមរាយការណ៍ តើផ្លូវកើតហេតុនេះមានក្នុងបញ្ជីប្លង់គោលដែរ ឬ ទេ ?

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៨៨ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម សំរេចចំពោះមុខដើមចោទ និងចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០១-០១-៩៧ របស់ដើមចោទឈ្មោះងួន ម៉េងឆាយ តំណាងអោយបុគ្គលិកសិក្សាសាលាបឋមសិក្សាជីដុះ ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោលដោយខាស់និងគតិច្បាប់ ។

២-ទទួលពាក្យបណ្ដឹងផ្ទាល់មាត់នាពេលសវនាការរបស់ចុងចំលើយ ជាតំណាងផ្ទេរសិទ្ធអោយ.................... ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់ចុងចំលើយឈ្មោះស៊ឹម ហុន អោយទៅចុងចំលើយផ្ទេរសិទ្ធិឈ្មោះកែវ ណារី ចុះថ្ងៃទី២៥-០២-១៩៩៧ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៤-ទទួលស្គាល់ពាក្យសុំកាន់កាប់ និង ប្រើប្រាស់ដីសង់លំនៅដ្ឋានរបស់ចុងចំលើយឈ្មោះ ស៊ឹម ហុន និង ប្ដីឈ្មោះកែវ ចាន់ ចុះថ្ងៃទី២៧-១១-៨៩ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៥-ទទួលស្គាល់គំនូសវាស់វែងដីកើតហេតុ ចុះថ្ងៃទី២៤-០១-១៩៩៧ របស់ភូមិបាលស្រុកកំពង់ចាម ទុកជាត្រឹមត្រូវតាមច្បាប់ ។

៦-ទទួលស្គាល់សិទ្ធិគ្រប់គ្រងដីកើតហេតុទំហំ២០,២០ម គុណ ៤៣ម ស្ថិតនៅភូមិ៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម របស់ចុងចំលើយឈ្មោះកែវ ចាន់ និង ប្រពន្ធឈ្មោះ ស៊ឹម ហុន តាមមាត្រា២ , ៣ និង១៩ នៃច្បាប់ភូមិបាល ។

៧-រឹបអូសប្រាក់ក្តីសរុប ៧០០០រៀល ដែលដើមចោទបង់ទុករួចមកហើយ ។

៨-សាលក្រមនេះ ប្រកាសជាសាធារណ:ចំពោះមុខដើមចោទ និងចុងចម្លើយ បើភាគីមិនសុខចិត្ត នឹងសាលក្រមនេះភាគីនោះមានសិទ្ធិប្តឹងឧទ្ធរណ៍ តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៨ របស់ឈ្មោះ ងួន ម៉េងឆាយ ប្តឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ៨៨ "គ" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី១៩-០១-១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦-០១-៩៨ របស់ឈ្មោះងួន ម៉េងឆាយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៨៨ "គ" ចុះថ្ងៃទី១១-១២-៩៧ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ្រិង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០រៀល និងលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណ:ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំនត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី០៨ ខែកុម្ភ: ឆ្នាំ១៩៩៩ របស់ឈ្មោះឈាង សុធន ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥៧ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី០៨ ខែកុម្ភ: ឆ្នាំ១៩៩៩ របស់លោកឈាង សុធន តំណាងអោយអង្គភាពសាលារៀនដីដុះ ទុកជាត្រឹមត្រូវតាមទំរង់ នឹង គតិច្បាប់ ។

២-ទុកជាមោឃ:សាលដីការដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៣៣ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ឈាង សុធន បានបង់រួចហើយ

គឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធភ្លើង ចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវអោយអ្នកស្រីកែវ ណារី សងប្រាក់១៩.០០០រៀលនេះទៅ លោកឈាង សុធន វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ :

១-សំរេចទទួលជំនុំជំរះរឿងក្ដីនេះឡើងវិញ តាមអំណាចសាលដីកាតុលាការកំពូលលេខ១៥៧ ចុះថ្ងៃទី៣១-៨-១៩៩៩ ។

២-សំរេចថាដីទំហំ ២០,២០ម គុណ ៤៣ម ស្ថិតនៅភូមិទី៣ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ត្រូវប្រគល់ឱ្យឈ្មោះ ស៊ឹម ហុន ដែលមាននាង កែវ ណារី គ្រប់គ្រងកាន់កាប់ធ្វើជាម្ចាស់តទៅ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលើកទី២លេខ៤៦១ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោក ងួន ម៉េឆាយ ប្ដឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី០៦ ខែផ្ទ មីនា ឆ្នាំ២០០១ របស់ឈ្មោះ ងួន ម៉េងឆាយ

បានឃើញសារណាតប ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០០១ របស់ឈ្មោះ កែវ ណារី

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ៨២ "ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្ដាប់ចំលើយរបស់លោក ងួន ម៉េងឆាយ នាពេលសវនាការ បានឆ្លើយថា : ខ្ញុំបាទមិនសុខចិត្តលើការជំនុំជំរះរបស់សាលាឧទ្ធរណ៍នោះទេ ពីព្រោះថាច្រកផ្លូវចេញចូលសាលាដីដុះនេះ គឺមានតាំងពីឆ្នាំ១៩៧៩ មកម្លេះ គឺសិស្សក៏ដូចជាប្រជាជននៅទីនោះចេញចូលរហូតមក ដល់ឆ្នាំ១៩៩៧ ទើបមានរឿងរាវកើតឡើងដោយឈ្មោះ ស៊ឹម ហ៊ុន វាទីយក ។ ក្នុងរឿងនេះ សាលាមានឯកសារគ្រប់គ្រាន់ជាភស្តុតាង ហើយរដ្ឋ

អំណាចក៏បានទទួលស្គាល់ទៅលើច្រកចេញចូលនេះដែរ ។ សាលាឧទ្ធរណ៍សំរេចបិទច្រកផ្លូវនេះ គឺជាការពុំត្រឹមត្រូវទេ ព្រោះច្រកផ្លូវនេះមានប្រជាជនប្រមាណ៩០% ដើរកាត់ផ្លូវនេះ ។ ខ្ញុំបាទសុំអោយតុលាការមេត្តាជួយកាត់ក្តីអោយសិស្សសាលាមានច្រកចេញចូលដូចឆ្នាំ១៩៧៩រហូតមក ។

បានស្តាប់ចំលើយរបស់អ្នកស្រី កែវ ណារី នាពេលសវនាការ បានឆ្លើយថា : ដីនេះជាដីឡូត៍ជាកម្មសិទ្ធិរបស់ម្តាយនាងខ្ញុំ តាំងពីសង្គមចាស់មកម៉េះ ហើយក្នុងឆ្នាំ១៩៩៧ ម្តាយខ្ញុំក៏បានមកកាន់កាប់រហូតមក តែដោយគាត់ក្រ ក៏ទុកដីនៅល្ហហ្ហេវពុំបានធ្វើរបងទេ ហើយគេក៏ដើរកាត់ទៅមកតែមិនមែនជាផ្លូវចេញចូលទេ ។ ហើយពាក្យដែលលោក ងួន ម៉េងឆាយ និយាយនោះ គឺជាការពុំពិតទេ គឺគាត់ទាមទារដើម្បីផលប្រយោជន៍គាត់ មិនមែនផ្លូវសាលាទេ តាមពិតសាលាមានផ្លូវមួយផ្សេងទៀតហើយ ។ ទោះជាមានការប្តូរទីតាំងក៏នាងខ្ញុំពុំព្រមដែរ ព្រោះដីនេះជាកម្មសិទ្ធិដីឡូត៍របស់ម្តាយនាងខ្ញុំ មិនមែនជាផ្លូវទេ ។

នាងខ្ញុំសូមសំណូមពរអោយតុលាការកំពូលចុះពិនិត្យដល់ទីកន្លែងទំនាស់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវ តាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ៤៦១ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោក ងួន ម៉េងឆាយ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលអាចអនុវត្តបានចំពោះរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោម និងសាលាឧទ្ធរណ៍យល់ថា ទីតាំងដីទីនាស់ដែលមានឈ្មោះស៊ុម ហ៊ុន និងនាង កែវ ណារី ជាតំណាងបានកាន់កាប់ និងគ្រប់គ្រងតាំងពីឆ្នាំ១៩៨៣-១៩៨៩ និងរហូតដល់សព្វថ្ងៃ ដោយសំអាងលើលិខិតលេខ៣៩២ ស.ជ.កច ចុះថ្ងៃទី២៤-១១-៩៧ ថា ដីកើតហេតុស្ថិតនៅក្នុងឡូត៍លំនៅដ្ឋាន ពុំមានពាក់ព័ន្ធលើគំរោងផ្លូវលើប្លង់គោលទីប្រជុំជនទេ និងសំអាងលើលិខិតសុំកាន់កាន់កាប់ដីធ្លី ព្រមទាំងអនុក្រិត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២-៤-៨៩ នោះជាការភន្តច្រឡំ ពីព្រោះថា :

✧ ទាំងដើមចោទ ទាំងចុងចម្លើយ ទាំងរដ្ឋអំណាចឃុំ-ស្រុកនិងប្រជាជនភូមិទី៣ សុទ្ធតែទទួលស្គាល់ថា សិស្ស-គ្រូ និងប្រជាជនបានដើរកាត់ដីនេះជាហូរហែតតអាក់ខានតាំងពីឆ្នាំ១៩៨០ ឬ១៩៨១ មកដល់ពេលប្តឹងគ្នាដែលបញ្ជាក់ថាកិរិយាកាន់កាប់ដីរបស់អ្នកស្រីស៊ុម ហ៊ុន ពុំមានលក្ខណៈផ្តាច់មុខតែម្នាក់ឯងឡើយ ។

-យល់ឃើញថា កំណត់ហេតុចុះថ្ងៃទី២៤-០២-៩៧ និងរបាយការណ៍លេខ៦៣ ស្រ.កច ចុះថ្ងៃទី២៥-០២-៩៧ របស់អភិបាលស្រុកកំពង់ចាមបានបញ្ជាក់អំពីប្រវត្តដើមរបស់ផ្លូវទំនាស់ថា ផ្លូវនេះមានពីសង្គម

ចាស់មកម្ល៉េះ ជាផ្លូវសំរាប់ផ្ទះខាងក្រោយនៃផ្ទះឈ្មោះកែវ ចាន់ ដែលសព្វថ្ងៃមានផ្ទះ២ជាភស្តុតាង ។ មកដល់ឆ្នាំ១៩៨០ លោកម៉ុម ចំរើន ប្រធានគណៈកម្មាធិការស្រុកទឹរួមខេត្តជាអ្នករៀបចំបង្កើតសាលារៀននេះ ហើយលោកបានអះអាងថា ផ្លូវនេះមានមុនសាលានេះកើតម្ល៉េះ ។ ដូច្នេះ ចុងចម្លើយពុំអាចមានសិទ្ធិលើដីផ្លូវនេះបានទេ ។

-យល់ឃើញថា ដើម្បីកុំឱ្យផ្លូវសេវភាពប្រើប្រាស់នេះ ពុះកាត់ដីរបស់ចុងចម្លើយជាពីរ តុលាការកំពូលគប្បីសំរេចផ្លូវដើរឆ្លងកាត់ដីនេះ ទៅជាប់របងដីរបស់ចុងចម្លើយផ្នែកខាងជើងដែលជាប់ព្រំប្រទល់ដីរបស់ឈ្មោះយិន ប៊ុន ដោយបន្ថែមចំណុច A , B , C និង D ដែលប្រវែង /AD/ = /BC/ =៣,៩០ម ហើយប្រវែង /AB/ = /DC/ = ៤៣ម លើគំនូសប្លង់ចុះថ្ងៃទី២៤-០១-៩៧ របស់ការិយាល័យភូមិបាលស្រុកកំពង់ចាម និងលើគំនូសប្លង់ ចុះថ្ងៃទី០៥-៣-២០០១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសូរិយោដី ខេត្តកំពង់ចាម ធ្វើជាផ្លូវដើរឆ្លងកាត់វិញ ។

-យល់ឃើញថា ការដែលចុងចម្លើយលើកឡើងនៅពេលសវនាការនេះថា សុំឱ្យតុលាការកំពូល ចុះស៊ើបអង្កេតដល់ទីកន្លែងដីទំនាស់ តុលាការកំពូលយល់ថា ពុំចាំបាច់ទេ ពីព្រោះអង្គភាពជំនាញបានគូរប្លង់បង្ហាញទីតាំងដីទំនាស់ច្បាស់លាស់ហើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩-១០-២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីទំនោះមុខក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៤៦១ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់លោក ងួន ម៉េងឆាយ ទុកជាត្រឹមត្រូវតាមទំរង់ នឹងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៨២"ក" ចុះថ្ងៃទី១៩-១០-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-សំរេចបើកផ្លូវទំហំ ៣.៩០ម គុណ ៤៣.០០ម តាងដោយអក្សរ ABCD ពីផ្លូវព្រះអង្គអេងតាមបណ្តោយដីចុងចម្លើយខាងជើងអែបជាប់ព្រំដីឈ្មោះយិន ប៊ុន តាមគំនូសបង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ២០០១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយាដីខេត្តកំពង់ចាមនិងតាមគំនូសប្លង់ចុះថ្ងៃទី២៤-០១-៩៧ របស់ការិយាល័យភូមិបាលស្រុកកំពង់ចាម ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកងួន ម៉េងឆាយ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតំរូវឱ្យអ្នកស្រីកែវ ណារី សងប្រាក់ចំនួន១៩.០០០រៀលនេះ ទៅឱ្យលោកងួន ម៉េងឆាយ វិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៣ ។